# អនុក្រឹត្យ លេខ ៣៧ អនក្រ.បក
## ស្តីពីការបង្កើតស្រុកភ្នំព្រឹក ចំណុះខេត្តបាត់ដំបង
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១** .- ត្រូវបានបង្កើតស្រុកភ្នំព្រឹក ។

**មាត្រា ២** .- ស្រុកភ្នំព្រឹក ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

**មាត្រា ៣** .- ស្រុកភ្នំព្រឹក ត្រូវបានបង្កើតឃុំចំនួន ០៥ ចំណុះ គឺ ឃុំភ្នំព្រឹក ឃុំពេជ្រចិន្តា ឃុំចក្រី ឃុំ រាំងធ្លាក់ និងឃុំអូររំដួល ។

**មាត្រា ៤** .- ស្រុកភ្នំព្រឹកត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកសំពៅលូន នៃខេត្តបាត់ដំបង ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកកំរៀង នៃខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកបវេល នៃខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៍ ។

**មាត្រា ៥** .- ទីតាំងសាលាស្រុកភ្នំព្រឹក ស្ថិតនៅក្នុងឃុំភ្នំព្រឹក ។

**មាត្រា ៦** .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧ ..** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ៣៨ អនក្រ.បក

## ស្តីពីការបង្កើតស្រុកកំរៀង ចំណុះខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ ..** ត្រូវបានបង្កើតស្រុកកំរៀង។

**មាត្រា ២ ..** ស្រុកកំរៀង ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

**មាត្រា ៣ ..** ស្រុកភ្នំកំរៀងត្រូវបានបង្កើតឃុំចំនួន ០៥ ចំណុះ គឺ ឃុំកំរៀង ឃុំបឹងរាំង ឃុំអូរដា ឃុំត្រាង និងឃុំតាសែន ។

**មាត្រា ៤ ..** ស្រុកកំរៀង ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកភ្នំព្រឹក នៃខេត្តបាត់ដំបង។